# ពិធីអបអរសាទរ “គម្រប់ខួប ២០ឆ្នាំ របស់កម្មវិធី PEPFAR ប្រចាំប្រទេសកម្ពុជា ”

**មជ្ឈមណ្ឌលជាតិ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២៣**

* * * * * * * * *




គណអធិបតី

- Dr. Joyce Neal, ប្រធានអង្គការ US-CDC ប្រចាំប្រទេសកម្ពុជា
- Dr Ouk Vichea ប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ
- Dr. Sok Bunna តំណាងអង្គការ USAID-PEPFRAR
- Dr. Lon Lavy អនុប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ
- លោក ញឹម ដារ៉ឡែន តំណាងអង្គការ FHI360
- Dr Nick Edwards Chief Party of LHSS/USAID
- លោកបណ្ឌិត ស្រី មុនី តំណាងគម្រោង LHSS/USAID
- ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ដែលថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃមជ្ឈមណ្ឌលជាតិ អង្គការដៃគូអភិវឌ្ឍន៍ តំណាងសង្គមស៊ីវិលទាំងអស់

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ បានសហការចូលរួមរៀបចំប្រារព្ធ ពិធីអបអរសាទរ “គម្រប់ខួប ២០ឆ្នាំ របស់កម្មវិធី PEPFARE ប្រចាំប្រទេសកម្ពុជា ” ជាមួយភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ដែលថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃមជ្ឈមណ្ឌលជាតិ អង្គការដៃគូអភិវឌ្ឍន៍ តំណាងសង្គមស៊ីវិលទាំងអស់ ។




ក្រោមការណែនាំចង្អុលបង្ហាញ និងគាំទ្រពីសំណាក់ថ្នាក់នាំក្រសួងសុខាភិបាល ព្រមទាំង មានការគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងអនុវត្តការងារបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ ពីដៃគូអភិវឌ្ឍន៍ម្ចាស់ជំនួយ សង្គមស៊ីវិល រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនចំណុច បានធ្វើឱ្យកម្ពុជាសម្រេចបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ក្នុងការ

ប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនៅក្នុងតំបន់។ តាមការប៉ាន់ស្មានដោយអង្គការ UNAIDS ឆ្នាំ២០២៣ កម្ពុជាបានប្រែក្លាយពីប្រទេសដែលមានអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ខ្ពស់ក្នុងតំបន់អាស៊ីកាលពីទសត្សរ៍ឆ្នាំ ២០០៣ មាន ១,១% ឱ្យថយចុះមកត្រឹម ០,៥% ឆ្នាំ២០២២។ គិតត្រឹមត្រីមាសទី១ ឆ្នាំ ២០២៣ មានអ្នកជំងឺអេដស៍ចំនួន ៦៥ ៦២៨ នាក់ កំពុងទទួលសេវាព្យាបាលដោយជំងឺអេដស៍ នៅតាមសេវាព្យាបាលជំងឺ ៧២ កន្លែងនៅទូទាំងប្រទេសកម្ពុជា។ ក្រុមប្រជាជនប្រឈមនឹងការឆ្លងមេរោគអេដស៍បានទទួលសេវាព្រឹប ចំនួន ៨៨៧៦ នាក់ នៅតាមសេវាព្រឹបចំនួន ២៥ កន្លែង (២០ កន្លែងផ្តល់នៅមូលដ្ឋានសុខាភិបាល/៥ CBOs) ហើយ PrEP Active Rate មាន ៤៩,៦% សេវាព្រឹបនឹងត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ទៅគម្រោងផែនការ ដើម្បីសម្រេចបានគោលដៅក្រុមប្រជាជនចំណុច ១០០០០ នាក់ ឬលើសពីនេះ នឹងបានទទួលសេវាព្រឹប នៅដំណាច់ឆ្នាំ ២០២៣ ។

បើប្រៀបធៀបទៅនឹងទិសដៅ ៩៥-៩៥-៩៥ ដែលយើងបានកំណត់ត្រឹមឆ្នាំ ២០២៥ យើងសម្រេចបាន ៨៦%នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពមេរោគអេដស៍ ៩៩%នៃអ្នកដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍និង ៩៧ % នៃអ្នកកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានបន្ទុកមេរោគអេដស៍ក្នុងឈាមត្រូវបានបង្ក្រាប។

យើងត្រូវខិតខំប្រឹងប្រែងបន្តឱ្យខ្លាំងថែមទៀត ដើម្បីឈានទៅសម្រេចបាន ៩៥ទី១ ក្នុងនោះនៅឆ្នាំ ២០២២ មានករណីឆ្លងថ្មីនៃមេរោគអេដស៍ចំនួន ១៤០០ នាក់ មានន័យថា មានការឆ្លងថ្មីនៃមេរោគអេដស៍ ៤នាក់/ថ្ងៃ ហើយ ៨៣% គឺស្ថិតនៅក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ និងដៃគូរបស់គាត់ ។ ការឆ្លងថ្មីនៃមេរោគអេដស៍នេះ បានថយចុះរហូតដល់៩១% គិតចាប់ការឆ្លងកម្រិតខ្ពស់បំផុតនៅឆ្នាំ ១៩៩៦ បន្ទាប់មក សន្ទុះនៃការថយចុះមានភាពយឺត មកនៅត្រឹមតែ ៣៣% បើប្រៀបធៀបនឹងឆ្នាំ ២០១០។ ផ្ទុយទៅវិញ យោងតាមការប៉ាន់ស្មាន ការឆ្លងថ្មីមានការកើនឡើងប្រមាណជា ៧៩% ក្នុងចំណោមក្រុមយុវវ័យអាយុ ១៥ ដល់២៤ឆ្នាំ ។

យើងត្រូវពង្រឹងការអនុវត្តអន្តរាគមន៍បង្ការទាំងឡាយណាដែលមានប្រសិទ្ធិភាពខ្ពស់បន្ថែមទៀត ដោយផ្តោតជាពិសេស ក្នុងចំណោមក្រុមចំនោមក្រុមប្រឈមមុខដែលជាយុវជន វ័យក្មេង ដោយបង្ក និងបង្កើតឱ្យមានចូលរួមក្នុងការងារអប់រំបង្ការការចម្លងមេរោគអេដស៍ រួមមាន៖

១. ការចុះអប់រំអំពីការបង្ការមេរោគអេដស៍ (ដោយផ្ទាល់ និងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម) ការធ្វើតេស្តរកមេរោគអេដស៍ និងការផ្សាភ្ជាប់ជាមួយសេវាព្យាបាល ។

២. ពង្រឹង និងពង្រីកការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង ទាំងនៅក្នុងសហគមន៍ និងតាមសេវាថែទាំ និងព្យាបាលជំងឺអេដស៍ដើម្បីធ្វើតេស្តដៃគូ។

៣. ពង្រឹង និងពង្រីកសេវាព្រើប បន្ថែមទៀត និងធ្វើសិក្សាស្រាវស្វែងរកមូលហេតុពីតម្រូវការសេវាព្រើប និង មូលហេតុដែលអ្នកដែលទទួលសេវាភាគច្រើនបោះបង់សេវាក្រោយពីទទួលបានមួយរយៈខ្លី។

៤. បន្តការអនុវត្ត ការធ្វើតេស្តរកឆ្លងថ្មីនៃមេរោគអេដស៍ ដើម្បីស្រាវជ្រាវក្រុមដែលទើបមានការឆ្លងថ្មី និងរៀបចំអន្តរាគមន៍ឱ្យបានសមស្រប ទាន់ពេល និងមានប្រសិទ្ធិភាព។

៥. បន្តតាមដានការផ្តល់សេវាក្នុងថ្ងៃតែមួយក្នុងចំណោមអ្នកជំងឺថ្មី ឱ្យបានគ្រប់គ្នា ។

៦. កាត់បន្ថយអត្រាបោះបង់សេវាព្យាបាល និងមានប្រព័ន្ធតាមដានអ្នកដែលបង់សេវាឱ្យមកទទួលសេវាវិញ តាមរយៈតាមដានកាលបរិច្ឆេទណាត់ជួយ ការផ្តល់ប្រឹក្សាតាមបែបជម្រុញឱ្យលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់និងជាប់លាប់ និងការតាមដានអ្នកជំងឺដែលបោះបង់ សេវា។

៧. ពង្រឹង គាំទ្រ និងតាមដានការធ្វើតេស្ត VL និង CD4 ឱ្យបានទៀងទាត់ និងស្របតាមគោលការណ៍ណែនាំគ្រប់គ្រងគ្លីនិក និងព្យាបាលជំងឺដែលបានអនុម័ត ដើម្បីលើកទឹកចិត្តឱ្យអ្នកជំងឺទទួលបានលទ្ធផល VL ក្នុងឈាមត្រូវបានបង្ក្រាប និងមិនអាចរកឃើញមេរោគ នៅពេលនោះគាត់នឹងលែងចម្លងមេរោគអេដស៍ទៅដៃគូរបស់គាត់ U=U ។

**លោក ប្រធានមជ្ឈមណ្ឌលជាតិថាន** ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាល នៃការអបអរសាទរពិធី គម្រប់ខួប ២០ឆ្នាំ របស់កម្មវិធី PEPFARE ប្រចាំប្រទេសកម្ពុជា បានរំលឹកពីប្រវត្តិដោយសង្ខេបនៃកិច្ចសហការណ៍រវាងមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ ជាមួយនឹងអង្គការ US-CDC ប្រចាំប្រទេសកម្ពុជា ក្នុងអំឡុងពេលពីរទសវត្សន៍កន្លងមកនេះដែលយើងអាចនិយាយបានថា គម្រោង PEPFAR ដែលជាគំនិតផ្តួចផ្តើមរបស់ប្រធាធិបតីសហរដ្ឋអាមេរិក ដើម្បីផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេសសម្រាប់ឆ្លើយតបទៅនឹងការឆ្លងរាលមេរោគអេដស៍នៅទូទាំងសកលលោក រួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ការចូលរួមគាំទ្រពីសំណាក់គម្រោង PEPFAR ដែលអនុវត្តន៍ដោយអង្គការដៃគូ ពិតជាមានសារៈសំខាន់ជាសារវន្ត ដែលនាំឱ្យប្រទេសកម្ពុជាបានទទួលជោគជ័យនៃការឆ្លើយទៅនឹងមេរោគអេដស៍ ដូចបានរៀបរាប់ខាងលើដោយសារការផ្តល់គាំទ្រនេះគឺកើតឡើងក្នុងអំឡុងពេលដែលប្រទេសកម្ពុជាកំពុងទទួលនូវការរាល

ដាលដោយមេរោគអេដស៍ក្នុងកម្រិតខ្ពស់ក្នុងបណ្ដាលប្រទេសអាស៊ីអាគ្នេយ៍ និងយើងក៏កំពុងរៀបចំបង្កើតឱ្យមានសេវាថែទាំព្យាបាលបន្តនៅឆ្នាំ ២០០២ ឬ ២០២៣ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនដល់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល ជាពិសេសឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការជាតិ និងអន្តរជាតិ មូលនិធិសកល, CRS, PEPFAR, USAIDS, US-CDC, KHANA, RHAC, FHI360, AHF, អង្គការសង្គមស៊ីវិល និងតំណាងបណ្ដាលក្រុមប្រជាជនចំណុចទាំងអស់ ឱ្យបន្តការគាំទ្រនិងអនុវត្តសកម្មភាពបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ ដើម្បីបង្កើនការរុករកករណីថ្មី បង្កើនការលេបថ្នាំឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ព្រមទាំងបន្តស្ថិតនៅក្នុងសេវាមួយជីវិត ឈានទៅសម្រេចគោលដៅ **៩៥ ៩៥ ៩៥** នៅឆ្នាំ ២០២៥ ។

ជាទីបញ្ចប់សូមប្រសិទ្ធពរជូន លោក លោកស្រី នូវពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**












